ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 05 / 2012
ម៉ោង (Time/Heure) : 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន ជាប្រធាន** |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១២ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN
Victor KOPPE
អាង ឧត្តម

Michael G. KARNAVAS
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN

## ១. សេចក្ដីផ្ដើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើបី ដែលសហព្រះរាជអាជ្ញាបានដាក់កាលពីថ្ងៃទី ០៥ ខែ កក្កដា ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ និងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ សុំដាក់ភស្តុតាងថ្មី ដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[១]។ សេចក្ដីសម្រេចនេះកំណត់ពីលក្ខណៈវិនិច្ឆ័យដែលត្រូវបំពេញ និងដំណើរការនីតិវិធីសម្រាប់ដាក់ឯកសារថ្មីៗ (*មានន័យថា* ឯកសារទាំងឡាយដែលដាក់ក្រោយពេលសវនាការបានចាប់ផ្ដើម) នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាននេះ។ អង្គជំនុំជម្រះក៏ដោះស្រាយផងដែរចំពោះប្រភេទឯកសារថ្មីៗផ្សេងទៀត ដែលជាឯកសារទាំងឡាយដែលមិនទាន់មាននៅក្នុងសំណុំរឿង ០០២ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងនេះ តែបានទទួលការអនុញ្ញាតឱ្យដាក់ក្នុងបញ្ជីឯកសារដែលភាគីបានស្នើសុំពីដំបូងដោយអនុលោមតាមវិធាន ៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង (ទាក់ទិននឹងសំណុំរឿង ០០២ ទាំងមូល) និងបញ្ជីឯកសារក្រោយទៀត (ដែលបានបង្ហាញថាឯកសារដែលនៅក្នុងបញ្ជីឯកសារដើមរបស់ខ្លួនពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១)។

២. លើសពីនេះទៀត ផ្ទុយពីដីកាបង្គាប់របស់អង្គជំនុំជម្រះដែលបានចេញពីពេលមុន អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ឯកសារមួយចំនួនដែលដាក់លើកក្រោយនេះ រួមមានឯកសារដែលមិនមាននៅក្នុងបញ្ជីឯកសារពីមុនដែលភាគីបានដាក់។ តាមរយៈបញ្ជីឯកសារ និងការដាក់ឯកសារដែលពាក់ព័ន្ធ ភាគីខ្លះក៏បានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវខ្លឹមសារឯកសារទាំងមូលដែលមាននៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ឬសំណុំរឿងតែម្តង។ សេចក្តីសម្រេចនេះក៏ដោះស្រាយបញ្ហាទាំងនេះ និងបញ្ហាពាក់ព័ន្ធដទៃទៀតផងដែរ។

---

[១] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យស្តាប់អ្នកជំនាញ ២ រូប និងសាក្សី ១៣ រូបបន្ថែម នៅក្នុងដំណាក់កាលដំបូងនៃសវនាការ និងការជូនដំណឹងអំពីចេតនាដាក់ឈុតវីដេអូខ្លីៗចំនួន ៧ ទាក់ទងទៅនឹង នួន ជា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយអនុលោមតាមវិធាន ៨៧(៤), ឯកសារលេខ E93/7, ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ (សំណើរបស់សហព្រះរាជអាជ្ញា); ការបង្ហាញជូនរបស់សហព្រះរាជអាជ្ញា អំពីការធ្វើសម្ភាសន៍ជាមួយ ខៀវ សំផន និងសៀវភៅដែលមានចំណងជើងថា "នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះក្នុងចំណោមជនរងគ្រោះជាច្រើននាក់របស់គាត់" ដោយលោក Gina CHON និង លោក ថេត សម្បត្តិ, ឯកសារលេខ E152, ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (សំណើទីពីររបស់សហព្រះរាជអាជ្ញា)។ ការបង្ហាញជូនរបស់សហព្រះរាជអាជ្ញា អំពីខ្សែភាពយន្តឯកសារដែលមានចំណងជើងថា "សត្រូវរបស់ប្រជាជន" E186 ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ (សំណើទីបីរបស់សហព្រះរាជអាជ្ញា)។

## ២. ប្រវត្តិនីតិវិធី

៣. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ភាគីឱ្យដាក់បញ្ជីឯកសារ និងវត្ថុតាង ដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅពេលសវនាការ ("ដីកា")[២]។ មេធាវីការពារក្តី អៀង សារី បានដាក់បញ្ជីនៅថ្ងៃទី ០១, ថ្ងៃទី ០៨ និង ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ហើយមេធាវីការពារក្តី ខៀវ សំផន សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់បញ្ជីរបស់ខ្លួននៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ("បញ្ជីឯកសារបឋម")[៣]។ មេធាវីការពារក្តី នួន ជា មិនបានដាក់បញ្ជីឯកសារទៅតាមដីកានេះទេ ផ្ទុយទៅវិញបានអះអាងថា ខ្លួននឹង "ប្រឹងប្រែងជូនដំណឹងទៅអង្គជំនុំជម្រះ និងភាគី អំពីឯកសារថ្មីដែលខ្លួនមានបំណងយកទៅសំអាងក្នុងសវនាការនៅពេលវេលាសមស្រប និងឱ្យបានមុនកាលកំណត់នៃការស្នើសុំសម្ភារៈនេះ"[៤]។

៤. នៅក្នុងសវនាការបឋមនាថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានបង្គាប់ឱ្យភាគីបញ្ជាក់ត្រឹមថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ អំពីឯកសារ និងវត្ថុតាងណាខ្លះនៅក្នុងបញ្ជីឯកសារបឋមរបស់ខ្លួន ដែលខ្លួនយល់ថាពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២/០១[៥]។ មេធាវីការពារក្តី ខៀវ សំផន សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជ

---

[២] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ឯកសារលេខ E9, ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១។

[៣] បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ E9/22, ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១; បញ្ជីឯកសារបឋមទី២ របស់លោក អៀង សារី, ឯកសារលេខ E9/24, ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១; បញ្ជីឯកសារបឋមលើកទីបីរបស់ អៀង សារី, ឯកសារលេខ E9/25, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ១០៣៧ នៅក្នុងឯកសារលេខ E9/25.2); បញ្ជីឯកសាររបស់ ខៀវ សំផន, ឯកសារលេខ E9/29, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ៣៣ នៅក្នុងឯកសារលេខ E9/29.2); បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការ ស្របតាមវិធាន ៨០(៣), ឯកសារលេខ E9/31, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ៤៨១ នៅក្នុងឯកសារលេខ E9/31.21); បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី (ឧបសម្ព័ន្ធ ៧ និង ៨), ឯកសារលេខ E9/32, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ៣១ នៅក្នុងឯកសារលេខ E9/32.2)។

[៤] ការជូនដំណឹងអំពីការចូលរួមជាមួយនឹងសារណាបឋមរបស់លោក អៀង សារី ទាក់ទងនឹងឯកសារដែលត្រូវលើកយកមកសំអាងនៅសវនាការ និង សារណាបន្ថែមទាក់ទងនឹងឯកសារថ្មី, ឯកសារលេខ E9/26, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ៤។

[៥] ប្រតិចារឹក, ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១, ទំព័រ ២៥។

អាជ្ញា បានដាក់បញ្ជីទាំងនេះ ("បញ្ជីឯកសារកែសម្រួល") នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ អង្គជំនុំជម្រះក៏បានទទួលយកបញ្ជីកែសម្រួលរបស់មេធាវីការពារក្ដី អៀង សារី ផងដែរ ដែលបានដាក់នៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១[៦]។ មេធាវីការពារក្ដី នួន ជា បដិសេធមិនដាក់បញ្ជីណាមួយទេ ដោយអះអាងថា ឯកសារដែលខ្លួនមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះនឹងត្រូវបញ្ចេញឱ្យដឹងនៅក្នុងពេលវេលាសមស្រប[៧]។

៥. នៅថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៤) ពីចេតនារបស់ខ្លួនក្នុងការដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឃ្លីបវីដេអូខ្លីៗ ចំនួន ៧ ដែលខ្លួនទើបតែទទួលបាននាពេលថ្មីៗនេះ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា ("ឃ្លីបវីដេអូ នួន ជា")[៨]។ មេធាវីការពារក្ដី នួន ជា មិនបានឆ្លើយតបទៅនឹងសំណើនេះទេ។

៦. នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់សំណើមួយ តាមវិធាន ៨៧(៤) ដែលស្នើសុំដាក់ខ្សែវីដេអូស្ដីពីបទសម្ភាសន៍មួយជាមួយជនជាប់ចោទ ខៀវ សំផន ("បទសម្ភាសន៍ ខៀវ សំផន ជាខ្សែវីដេអូ") និងសៀវភៅមួយក្បាលដែលមានចំណងជើងថា "នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះក្នុងចំណោមជនរងគ្រោះជាច្រើននាក់របស់គាត់" ដែលសរសេរដោយលោក Gina CHON និង លោក ថេត សម្បត្តិ ("សៀវភៅ")[៩]។ មេធាវីការពារក្ដី

---

៦ បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការ, ឯកសារលេខ E109/1, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ៣៤ នៅក្នុងឯកសារលេខ E109/1.1); បញ្ជីឯកសារ និងវត្ថុតាងដែលកែសម្រួលរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសវនាការ ៤ វគ្គដំបូង, ឯកសារលេខ E109/2, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ១៩ នៅក្នុងឯកសារលេខ E109/2.3); ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលនៃការជំនុំជម្រះលើអង្គសេចក្ដី, ឯកសារលេខ E109/4, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ៤៥២ នៅក្នុងពីឯកសារលេខ E109/4.1 ដល់ E109/4.20) និង បញ្ជីឯកសារ និង វត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង, ឯកសារលេខ E109/6, ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១ (ដែលរៀបរាប់ឯកសារថ្មីចំនួន ៦ នៅក្នុងឯកសារលេខ E109/6.2)។

៧ ការកត់សម្គាល់អំពីឯកសារដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូង, ឯកសារលេខ E109/3, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

៨ សំណើលើកទី១ របស់សហព្រះរាជអាជ្ញា")។

៩ សំណើលើកទី២ របស់សហព្រះរាជអាជ្ញា"។ នៅថ្ងៃដដែលនោះ សហព្រះរាជអាជ្ញាបានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគីថា ឯកសារថ្មីៗដែលពួកគេមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះអាចរកបាននៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម (សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានា ទាក់ទងនឹងលទ្ធភាពពិនិត្យឯកសារ

ខៀវ សំផន បានឆ្លើយតបទៅនឹងសំណើនេះនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១[១០]។

៧. នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ មេធាវីការពារក្តី នួន ជា បានដាក់ "បញ្ជីឯកសារដែលត្រូវដាក់នៅដំណាក់កាលដំបូងនៃការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ("បញ្ជីឯកសាររបស់ នួន ជា") ដែលសហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១២[១១]។ មេធាវីការពារក្តី នួន ជា បានឆ្លើយតបវិញនៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២[១២]។

៨. នៅថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ បន្ទាប់ពីបានពិនិត្យទៅលើឯកសារថ្មីទាំងអស់រួចមក (*មានន័យថា* ឯកសារទាំងឡាយដែលមិនមានក្នុងសំណុំរឿងនៅពេលអង្គជំនុំជម្រះបានទទួលសំណុំរឿង តែ ភាគីបានស្នើសុំដាក់នៅចំពោះអង្គជំនុំជម្រះមុនពេលចាប់ផ្តើមសវនាការ អនុលោមតាមវិធាន ៨០(៣)(ឃ) ដែលមាននៅក្នុងឧបសម្ព័ន្ធ ១ ដល់ឧបសម្ព័ន្ធ ៥ នៃបញ្ជីឯកសារកែសម្រួលរបស់សហព្រះរាជអាជ្ញា (ផ្នែក ៤.២.១) អង្គជំនុំជម្រះបានទទួលយកឯកសារចំនួន ៣៥ ក្នុងចំណោមឯកសារទាំងនេះ[១៣]។

---

ថ្មីដែលបានចុះបញ្ជីនៅក្នុងបញ្ជីឯកសាររបស់ ក.ស.ព សម្រាប់សវនាការ E9/31.21, E109/4.1, E131/1/4.1, ឯកសារលេខ E151, ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១)។

[១០] ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំទទួលឯកសារថ្មីពីរ, ឯកសារលេខ E152/1, ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១។

[១១] បញ្ជីឯកសារដែលត្រូវដាក់នៅដំណាក់កាលដំបូងនៃការជំនុំជម្រះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង E131/1/13, ឯកសារលេខ, ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ (រួមមានឯកសារថ្មីចំនួន ១៤ នៅក្នុងឯកសារលេខ E131/1/13.1) ("ពាក្យសុំរបស់ នួន ជា"); ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបញ្ជីឯកសាររបស់ នួន ជា ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ, ឯកសារលេខ E131/1/14, ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១២។

[១២] សារណាឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសារដែលត្រូវដាក់នៅសវនាការលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ E131/1/14/1, ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២។

[១៣] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរវគ្គដំបូងនៃសំណុំរឿង ០០២/០១, ឯកសារលេខ E185, ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២, ដែលបានទទួលយកឯកសារលេខរៀង 11, 49, 51, 160, 161, 162, 166, 168, 169, 170, 187, 188, 189, 190, 191 និង 207 នៅក្នុងឯកសារលេខ E109/4.1; 80 នៅក្នុងឯកសារលេខ E109/4.2; 9, 32, 66, 73, 75, 79, 137, 217, 223, 225 និង 338 នៅក្នុងឯកសារលេខ E109/4.4; និងលេខរៀង 73, 123, 245, 278, 283, 355 និង 357 នៅក្នុងឯកសារលេខ E109/4.5។

៩. នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើមួយ អនុលោមតាមវិធាន ៨៧(៤) ស្នើសុំដាក់ខ្សែភាពយន្តឯកសារមួយដែលមានចំណងជើងថា "សត្រូវរបស់ប្រជាជន" និង ឈុតវីដេអូខ្លីៗដែលពាក់ព័ន្ធ ("ខ្សែភាពយន្តឯកសារ") ទៅក្នុងសំណុំរឿង[១៤]។

## ៣. សារណា

១០. សហព្រះរាជអាជ្ញាស្នើសុំដាក់ ឈុតវីដេអូ នួន ជា ទៅក្នុងសំណុំរឿង ពីព្រោះថាសហព្រះ-រាជអាជ្ញាមានបំណងចង់ដាក់ភស្តុតាងនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអនុលោមតាម វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាលើកឡើងថា មកដល់ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ ពួកគេពុំមានភាពយន្តឯកសារនេះនៅឡើយទេ។ សហព្រះរាជអាជ្ញាបន្តថា ខ្លួនទើបបានដឹង ថាមានឈុតវីដេអូ នួន ជា នៅក្នុងអ៊ីនធឺណែត នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១១[១៥]។ សហព្រះ រាជអាជ្ញាក៏អះអាងបន្ថែមទៀតថា ឈុតវីដេអូទាំងនេះ នឹង "ជួយនៅក្នុងការបង្ហាញការពិតពាក់ ព័ន្ធនឹងតួនាទីជាន់ខ្ពស់របស់ នួន ជា នៅក្នុងរបបសន្តិសុខនៃ ប.ក.ក ដោយរួមទាំងការចូលរួម ចំណែករបស់គាត់នៅក្នុងការបង្កើតគោលនយោបាយ "កម្ទេច" សមាសភាពគហបតី ការទទួល និងការពិនិត្យមើលយ៉ាងហ្មត់ចត់លើចម្លើយសារភាពរបស់ពួកកម្មាភិបាលដែលត្រូវបានចាប់ខ្លួន ហើយនឹងការដឹងរបស់គាត់ពីការប្រហារជីវិតមនុស្សដែលគិតថាជា "ខ្មាំង""[១៦]។

១១. ទាក់ទិននឹងបទសម្ភាសន៍ ខៀវ សំផន ជាខ្សែវីដេអូវិញ សហព្រះរាជអាជ្ញាលើកឡើងថា វីដេអូនេះ មានការពាក់ព័ន្ធនឹងការស្វែងរកការពិត ដោយសារខ្សែវីដេអូនេះមានការលើកឡើងរបស់ ជនជាប់ចោទ ខៀវ សំផន ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ ("DK") ប្រវត្តិ គោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និង "តួនាទី និងការទទួលខុសត្រូវរបស់ជន ជាប់ចោទ ទាំងមុន អំឡុងពេល និងក្រោយសម័យកម្ពុជាប្រជាធិបតេយ្យ")។ សហព្រះរាជអាជ្ញាក៏ បានអះអាងបន្ថែមទៀតថា ពួកគេពុំមានបទសម្ភាសន៍ ខៀវ សំផន ជាខ្សែវីដេអូទេ មុនពេលចាប់ ផ្តើមសវនាការ តែភាគីទីបី បានបង្ហោះវីដេអូនេះនៅលើអ៊ីនធឺណែត ដោយអះអាងថាជាជនជាប់ ចោទ ខៀវ សំផន ហើយសហព្រះរាជអាជ្ញាបានរកឃើញនៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១[១៧]។

១២. ទាក់ទិននឹងសៀវភៅវិញ សហព្រះរាជអាជ្ញាលើកឡើងថា សៀវភៅនេះពឹងផ្អែកភាគច្រើន

---

[១៤] សំណើលើកទី៣ របស់សហព្រះរាជអាជ្ញា។

[១៥] សំណើលើកទី១ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៣ និង ៣៥។

[១៦] សំណើលើកទី១ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣៤។

[១៧] សំណើលើកទី២ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២-៣។

ទៅលើកិច្ចសម្ភាសន៍ជាមួយ នួន ជា ហើយវាពាក់ព័ន្ធនឹងការស្វែងរកការពិតទាក់ទិននឹងតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងអំឡុងពេលដែលពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ទោះបីសៀវភៅនេះត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ ២០១០ ក៏ដោយ ក៏សហព្រះរាជអាជ្ញាអះអាងថា បណ្ណាល័យរបស់ អ.វ.ត.ក មិនមានសៀវភៅនេះទេ រហូតដល់ខែ សីហា ឆ្នាំ ២០១១ ឬថា សហព្រះរាជអាជ្ញាមិនបានដឹងទេ រហូតដល់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១[១៨]។

១៣. សហព្រះរាជអាជ្ញាលើកឡើងថា ខ្សែភាពយន្តឯកសារនោះក៏មានប្រយោជន៍ដល់ការស្វែងរកការពិតដែរ ដោយសារវាមានចម្លើយរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងសាវតារប្រវត្តិនៃកម្ពុជាប្រជាធិបតេយ្យ តួនាទី និងការទទួលខុសត្រូវផ្សេងៗរបស់ជនជាប់ចោទ រចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ និងគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ។ សហព្រះរាជអាជ្ញាលើកជាទឡ្ហីករណ៍ថា មុនពេលបើកសវនាការ ខ្សែភាពយន្តឯកសារនេះមិនអាចផ្តល់ជូនបានទេ ដោយសារសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត មានការលំបាកក្នុងការទទួលបានខ្សែភាពយន្តឯកសារនេះ[១៩]។

១៤. មេធាវីការពារក្តី ខៀវ សំផន បដិសេធការទទួលយកសៀវភៅនេះ និងបទសម្ភាសន៍ ខៀវ សំផន ជាខ្សែវីដេអូ សម្រាប់ជាភស្តុតាងថ្មី ដោយសំអាងថា សហព្រះរាជអាជ្ញាមិនបានបង្ហាញថា ពួកគេបានបំពេញការងារដោយយកចិត្តទុកដាក់ ឬថា ពួកគេមិនអាចអនុវត្តតាមការកំណត់កាលបរិច្ឆេទចុងក្រោយរបស់អង្គជំនុំជម្រះសម្រាប់ការដាក់បញ្ជីឯកសារទេ។ សហព្រះរាជអាជ្ញាក៏ខកខានផងដែរមិនបានបង្ហាញថា ពួកគេបានស្វែងរកសៀវភៅនេះ និងបទសម្ភាសន៍ ខៀវ សំផន ជាខ្សែវីដេអូ នាឱកាសដំបូងបំផុតទេ។ មេធាវីការពារក្តីលើកឡើងថា សហព្រះរាជអាជ្ញាខកខានក្នុងបង្ហាញ ថាការទទួលយកសម្ភារៈ/ឯកសារថ្មី ជាការសំខាន់ដើម្បី ជាប្រយោជន៍ចំពោះយុត្តិធម៌ និងថា សម្ភារៈ/ឯកសារ ត្រូវបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យនៃការទទួលយកជាភស្តុតាងដែលមានចែងក្នុងវិធាន ៨៧(៣)[២០]។

១៥. មេធាវីការពារក្តី នួន ជា លើកឡើងពីសិទ្ធិមួយដែលផ្អែកលើច្បាប់កម្ពុជា ដើម្បីស្នើសុំឱ្យ

---

[១៨] សំណើលើកទី២ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤-៥។

[១៩] សំណើលើកទី៣ របស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ២-៣ និង ៥-៦។

[២០] ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំទទួលឯកសារថ្មីពីរ, ឯកសារលេខ E152/1, កថាខណ្ឌ ៧, ៨ និង ១០-១៤។

ទទួលយកឯកសារនៅគ្រប់ដំណាក់កាលនៃការប្រព្រឹត្តទៅនៃសវនាការ[២១]។ សហព្រះរាជអាជ្ញាឆ្លើយតបថា សំណើនេះគួរត្រូវបដិសេធ ហើយបញ្ជីឯកសាររបស់ នួន ជា គួរត្រូវបានច្រានចោល ដោយសារមេធាវី នួន ជា តែងតែខកខានក្នុងការដាក់បញ្ជីឯកសារឲ្យបានទាន់ពេលវេលាអនុលោមតាមដីកាបង្គាប់ពីមុនៗរបស់អង្គជំនុំជម្រះ[២២]។

## ៤. សំអាងហេតុ

### ៤.១ ក្របខណ្ឌច្បាប់

#### *៤.១.១ សេចក្ដីផ្ដើម*

១៦. អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវយកចេញពីសំណុំរឿង ដែលសហចៅក្រមស៊ើបអង្កេត ឬក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះបានបញ្ជូនមកអង្គជំនុំជម្រះសាលាដំបូងជាមួយនឹងដីកាដំណោះស្រាយ។

១៧. នៅក្នុងស្ថានភាពមួយចំនួន សម្ភារៈ/ឯកសារ ដែលមិនស្ថិតក្នុងសំណុំរឿងដែលត្រូវបានបញ្ជូនតាំងពីដំបូងមកអង្គជំនុំជម្រះសាលាដំបូង ក៏អាចដាក់ក្នុងសំណុំរឿងដែរ និងអាចដាក់នៅចំពោះមុខ អង្គជំនុំជម្រះបានដែរ ទាំងដោយការផ្តួចផ្តើមរបស់អង្គជំនុំជម្រះខ្លួនឯង ឬតាមសំណើពីភាគីណាមួយ។ ឧទាហរណ៍ មុនពេលចាប់ផ្តើមសវនាការ ភាគីអាចបញ្ចូលឯកសារ "ថ្មី" ទៅក្នុងបញ្ជីឯកសាររបស់ខ្លួនបាន (*មានន័យថា* ឯកសារទាំងឡាយដែលមិនទាន់ស្ថិតក្នុងសំណុំរឿងនៅពេលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿងនេះ) អនុលោមតាមវិធាន ៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង។ នៅពេលសវនាការចាប់ផ្តើម ភាគីក៏អាចស្នើសុំដាក់ភស្តុតាងថ្មីបានដែរ (*មានន័យថា* ភស្តុតាងដែលមិនទាន់មាននៅមុនពេលចាប់ផ្តើមសវនាការ) តាមរយៈសារណាដែលមានសំអាងហេតុត្រឹមត្រូវស្របតាមលក្ខណៈវិនិច្ឆ័យដែលមានចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

១៨. ភស្តុតាងទាំងអស់ត្រូវតែស្របទៅតាមលក្ខណៈវិនិច្ឆ័យទូទៅសម្រាប់ទទួលយកជាភស្តុតាង ដែលមានចែងក្នុងវិធាន ៨៧(៣)(ក)-(ង) នៃវិធានផ្ទៃក្នុង។ អាស្រ័យហេតុនេះ ឱកាសសម្រាប់ភាគីក្នុងការជំទាស់ទៅនឹងឯកសារទាំងឡាយអនុលោមតាមលក្ខណៈវិនិច្ឆ័យទាំងនេះ ក៏ជាបុរេលក្ខខណ្ឌមួយសម្រាប់ការទទួលឯកសារថ្មីទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះដែរ។ ទោះជា

---

[២១] ពាក្យសុំរបស់ នួន ជា, កថាខណ្ឌ ៥-៦; សារណាឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសារដែលត្រូវដាក់នៅសវនាការលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ E131/1/14/1, ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ២-៥។

[២២] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបញ្ជីឯកសាររបស់ នួន ជា ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅដំណាក់កាលដំបូងនៃការជំនុំជម្រះ, ឯកសារលេខ E131/1/14, ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១២។

00804392



យ៉ាងណាក្តី នៅពេលដែលអង្គជំនុំជម្រះបដិសេធការជំទាស់ណាមួយដែលពាក់ព័ន្ធនឹងឯកសារណាមួយ ឬនៅពេលដែលពុំមានការជំទាស់ត្រូវបានលើកឡើងនោះ ឯកសារនោះត្រូវបានចាត់ទុកថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះ និងត្រូវចុះលេខជាប្រភេទឯកសារ E3[២៣]។ ក្របខណ្ឌនីតិវិធីទូទៅដែលគ្រប់គ្រងការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបានពន្យល់លំអិតនៅក្នុងសេចក្តីសម្រេចផ្សេងទៀតរបស់អង្គជំនុំជម្រះ ដែលដោះស្រាយទៅលើបទប្បញ្ញត្តិនានានៃវិធានផ្ទៃក្នុង ដែលទាក់ទិននឹងវិធានស្តីពីភស្តុតាង[២៤]។

### *៤.១.២ លក្ខណៈនៃក្របខណ្ឌច្បាប់នៅ អ.វ.ត.ក ដែលឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះបទឧក្រិដ្ឋធំៗ*

១៩. ដើម្បីជួយសម្រួលដំណើរការនីតិវិធីឲ្យបានឆាប់រហ័សពាក់ព័ន្ធនឹងឯកសារដ៏ច្រើន និងដើម្បីការពារសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ភាគីទាំងអស់ វិធាន ៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង បានផ្តល់អំណាចដល់អង្គជំនុំជម្រះ ក្នុងការបង្គាប់ភាគីឲ្យដាក់បញ្ជីឯកសារដែលខ្លួនមានបំណងយកមកសំអាងមុនពេលចាប់ផ្តើមសវនាការ។ ក្នុងករណីបច្ចុប្បន្ននេះ អង្គជំនុំជម្រះបានបង្គាប់ភាគីឲ្យដាក់បញ្ជីឯកសារបឋមរបស់ខ្លួន (ទាក់ទិននឹងសំណុំរឿង ០០២ ទាំងមូល) និងបន្ទាប់មកដាក់បញ្ជីឯកសារកែសម្រួលរបស់ខ្លួន (ពាក់ព័ន្ធនឹងសវនាការដំណាក់កាល

---

[២៣] មានតែភស្តុតាងដែលមានលេខ E3 ទេទើបអាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្តីសម្រេចបាន៖ *សូមមើល* វិធាន ៨៧(២) នៃវិធានផ្ទៃក្នុង (ដែលចែងថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនេះត្រូវឆ្លងកាត់ការដេញដោល")។ សូមមើលអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំបញ្ជាក់អំពីប្រភេទនៃឯកសារ E3 ជាក់លាក់មួយចំនួន (ឯកសារ E178) និងសំណើសុំ E167។

[២៤] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង, ឯកសារលេខ E43/4, ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩, កថាខណ្ឌ ៥-៧; សាលក្រម, កាំង ហ្កេកអ៊ាវ *ហៅ* ឌុច, សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសជ, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០, កថាខណ្ឌ ៣៦-៤៣; អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158", ឯកសារលេខ E162, ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ និង សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១, ឯកសារលេខ E185, ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២, កថាខណ្ឌ ២០-២១, ៣១។

ដំបូងក្នុងសំណុំរឿង ០០២/០១) (ផ្នែកទី២)។ មានតែឯកសារដែលមានក្នុងបញ្ជីទាំងនេះទេ (ឯកសារទាំងឡាយដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង) ទើបអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុវត្តតាមបែបបទដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង និងអាចប្ដឹងជំទាស់បាន (ផ្នែកទី ៤.១.១)។ សម្រាប់ជាប្រយោជន៍ដល់ភាគី និងអង្គជំនុំជម្រះ បញ្ជីឯកសារទាំងនេះមានគោលបំណងសម្រួលដល់ការរៀបចំសវនាការ ដោយកំណត់អត្តសញ្ញាណភស្តុតាងទាំងអស់ ដែលអាចនឹងត្រូវបានលើកឡើងយកមកពិភាក្សានៅពេលសវនាការ។ ការអនុវត្តនេះក៏ជួយឲ្យកិច្ចដំណើរការនីតិវិធីកាន់តែមានភាពឆាប់រហ័សដែរ តាមរយៈការកាត់បន្ថយវិសាលភាពនៃការពិភាក្សានៅសវនាការដោយពិភាក្សាតែទៅលើឯកសារទាំងឡាយដែលត្រូវបានជំទាស់ជាក់លាក់ដោយភាគីណាមួយប៉ុណ្ណោះ និងតាមរយៈការធានាថា ភស្តុតាងអាចត្រូវបានស្នើឡើងយឺតមកអង្គជំនុំជម្រះ ប៉ុន្តែត្រូវបំពេញតាមលក្ខខណ្ឌតឹងរ៉ឹង។

២០. នៅក្នុងន័យនេះ ក្របខណ្ឌនីតិវិធីនៅ អ.វ.ត.ក ដែលខុសគ្នាលើចំណុចមួយចំនួនពីច្បាប់កម្ពុជានោះឆ្លុះបញ្ចាំងពីលក្ខខណ្ឌតម្រូវដោយឡែកសម្រាប់ការជំនុំជម្រះបទឧក្រិដ្ឋធំៗ និងបទដ្ឋានអន្តរជាតិដែលបង្កើតឡើងដើម្បីការពារសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ភាគី និងភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធី[២៥]។ អាស្រ័យហេតុនេះ សិទ្ធិដែលទាមទារដោយមេធាវីការពារក្តី នួន ជា ដោយផ្អែកលើច្បាប់កម្ពុជា ក្នុងការដាក់ឯកសារដែលខ្លួនចាត់ទុកថាពាក់ព័ន្ធនៅគ្រប់ដំណាក់កាលនៃសវនាការ ត្រូវបានបដិសេធ[២៦]។

២១. ដូចគ្នាដែរ ការប៉ុនប៉ងរបស់មេធាវីការពារក្តី អៀង សារី ក្នុងការបញ្ចូលខ្លឹមសារនៃឃ្លាំងផ្ទុកឯកសាររួមទៅក្នុងបញ្ជីឯកសាររបស់ខ្លួន ក៏ត្រូវបានច្រានចោលផងដែរ ដោយសារវាបំពានទៅ

[២៥] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអនុញ្ញាតឲ្យភាគីដាក់ឯកសារ និងភស្តុតាងទាំងអស់ដែលពួកគេយល់ថា មានប្រយោជន៍ក្នុងការបង្ហាញឲ្យឃើញការពិត; *ទោះជាយ៉ាងក្តី សូមមើល* សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ, ឯកសារលេខ E51/14, ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១; *សូមមើលផងដែរ* ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០១ ដោយមានបញ្ចូលនូវវិសោធនកម្មដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០៦), មាត្រា ២០ថ្មី, ២៣ថ្មី, និង ៣៣ថ្មី និង កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១២(១)។

[២៦] ពាក្យសុំរបស់ នួន ជា, កថាខណ្ឌ ៥-៦។

លើដីកាបង្គាប់ពីមុនៗរបស់អង្គជំនុំជម្រះផង និងក្របខណ្ឌច្បាប់ជាធរមានផង[២៧]។ បែបបទនេះគឺមិនសមស្របទៅនឹងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងឆាប់រហ័សទេ ដោយសារចំនួនដ៏ច្រើននៃឯកសារនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ធ្វើឱ្យអង្គជំនុំជម្រះ និងភាគី មិនអាចកត់សម្គាល់ឱ្យបានពេញលេញថាតើឯកសារណានឹងត្រូវលើកយកមកពិភាក្សានាពេលសវនាការនោះឡើយ[២៨]។ ទោះជាយ៉ាងណាក្តី ទាក់ទិននឹងឯកសារទាំងអស់ដែលមិនបានបញ្ចូលក្នុងបញ្ជីរបស់ភាគីដែលបានដាក់ទៅតាមដីកាបង្គាប់ពីមុនៗរបស់អង្គជំនុំជម្រះ ភាគីមិនត្រូវបានរារាំងក្នុងការដាក់ពាក្យសុំបន្ថែមនាពេលអនាគតដើម្បីសុំការទទួលយកឯកសាររបស់ខ្លួនអនុលោមតាមវិធាន ៨៧(៤) នោះទេ ប្រសិនបើភាគីយល់ថាឯកសារថ្មីដែលខ្លួនស្នើសុំដាក់នោះ ផ្តល់ប្រយោជន៍ដល់យុត្តិធម៌។

### *៤.១.៣ លក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលយកឯកសារថ្មីៗ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង*

២២. នៅពេលមានសំណើដាក់ឯកសារថ្មីៗនៅចំពោះមុខអង្គជំនុំជម្រះបន្ទាប់ពីចាប់ផ្តើមសវនាការ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចែងថា ភាគីដែលស្នើសុំការទទួលយកភ័ស្តុតាងថ្មីជាដំបូង ត្រូវ "ធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា [...] ភ័ស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាន

---

[២៧] ទោះបីមេធាវីការពារក្តី អៀង សារី បានដាក់បញ្ជីឯកសារបឋមអនុលោមតាមដីកាពីមុនរបស់អង្គជំនុំជម្រះ (*សូមមើល* បញ្ជីឯកសារបឋមលើកទីបីរបស់ អៀង សារី, ឯកសារលេខ E9/25, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ (ដែលមានរៀបរាប់ឯកសារថ្មីចំនួន ១០៣៧ នៅក្នុងឯកសារលេខ E9/25.2)) ក៏ដោយ ពួកគេក៏បានបង្ហាញនូវចេតនាចង់បញ្ចូលបញ្ជីឯកសារនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមទាំងមូលទៅក្នុងបញ្ជីឯកសារនាពេលសវនាការដែរ (*សូមមើល* បញ្ជីឯកសារបឋមលើកទីពីររបស់ អៀង សារី, ឯកសារលេខ E9/24, ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១)។

[២៨] បញ្ហាស្រដៀងគ្នានៃសច្ចភាព និងការជូនដំណឹងតាមពេលវេលាសមរម្យ ត្រូវបានលើកឡើង នៅពេលភាគីខ្លះមានបំណងបញ្ចូលខ្លឹមសារនៃសំណុំរឿងទាំងមូលទៅក្នុងវិសាលភាពនៃឯកសារដែលអាចនឹងលើកយកមកពិភាក្សានាពេលសវនាការ (*សូមមើល* បញ្ជីឯកសារបឋមរបស់ អៀង សារី ដែលមាននៅក្នុងសំណុំរឿងរួចហើយ និងការជូនដំណឹងពីបញ្ជីបឋមនៃឯកសារថ្មីរបស់គាត់ដែលនឹងមកដល់ ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ E9/22, ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ១២-២៥; *សូមមើលផងដែរ* ការជូនដំណឹងអំពីការចូលរួមជាមួយនឹងសារណាបឋមរបស់លោក អៀង សារី ទាក់ទងនឹងឯកសារដែលត្រូវលើកយកមកសំអាងនៅសវនាការ និង សារណាបន្ថែមទាក់ទងនឹងឯកសារថ្មី, ឯកសារលេខ E9/26, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ១-២; បញ្ជីឯកសាររបស់ ខៀវ សំផន, ឯកសារលេខ E9/29, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១, កថាខណ្ឌ ៦-៩)។ ការប្រើប្រាស់ឯកសារក្នុងសំណុំរឿងពេលសវនាការដែលមិនមានក្នុងបញ្ជីឯកសាររបស់ភាគីនឹងត្រូវដោះស្រាយដោយអង្គជំនុំជម្រះ នៅពេលវេលាសមស្រប នៅក្នុងបរិបទនៃការរៀបចំសវនាការដែលកំពុងដំណើរការ។

នៅមុនពេលចាប់ផ្តើមការជំនុំជម្រះ”[២៩]។

២៣. យុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបង្ហាញថា សញ្ញាណនៃ “ការអាចរកបាន” នៃភ័ស្តុតាង មានទំនាក់ទំនងនឹងការបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដ។ ឧទាហរណ៍ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា នៅពេលភាគីមួយស្នើសុំដាក់ភ័ស្តុតាងបន្ថែមដែលមិនអាចរកបានពីមុន បន្ទាប់ពីសំណុំរឿងរបស់ខ្លួនបានបិទហើយនោះ “ការពិចារណាជា សំខាន់គឺថា នៅពេលបំពេញការងារដោយយកចិត្តទុកដាក់ហើយ តើភ័ស្តុតាងនោះអាចត្រូវបានកំណត់អត្តសញ្ញាណ និងបង្ហាញបានឬទេ នៅពេលដែលភាគីនោះបានធ្វើសំណើសុំ”[៣០]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY និងតុលាការ ICTR បានសម្រេចជាច្រើនដងហើយថា ភ័ស្តុតាងអាចត្រូវបានចាត់ទុកថាមិនអាចរកបានពេលជំនុំជម្រះ តែក្នុងករណីដែលភាគីស្នើសុំមិនអាចរកឃើញភ័ស្តុតាងនោះ បន្ទាប់ពីបានបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដហើយ

---

[២៩] *សូមមើលផងដែរ* វិធាន ៨០*ស្ទួន*(១) នៃវិធានផ្ទៃក្នុង៖ “ការជម្រះសេចក្តីចាប់ផ្តើមជាមួយនឹងសវនាការបឋម”។ សវនាការបឋមក្នុងសំណុំរឿង ០០២/០១ ចាប់ផ្តើមដំណើរការនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១។

[៣០] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalic និងអ្នកដទៃទៀត,* សាលដីកា, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-96-21-A), ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ (“*រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalic*”), កថាខណ្ឌ ២៨៣។ នៅឯតុលាការអន្តរជាតិដទៃទៀត ភ័ស្តុតាងដែលមិនបានបង្ហាញស្របតាមកាលបរិច្ឆេទកំណត់ចុងក្រោយ មិនអាចទទួលយកបានទេនៅពេលជំនុំជម្រះ និងអាចត្រូវបានដកចេញទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រម អាស្រ័យទៅតាមកាលៈទេសៈ។ ក្នុងករណីលើកលែង អង្គជំនុំជម្រះសាលាដំបូងនៃតុលាការនានាបានទទួលយកសំណើសុំកែសម្រួលបញ្ជីវត្ថុតាងដើម ក្នុងអំឡុងពេលបង្ហាញរឿងក្តីរបស់ភាគីមួយ នៅពេលដែលអង្គជំនុំជម្រះជឿថា មានការបង្ហាញអំពីមូលហេតុត្រឹមត្រូវ និងថាសម្ភារៈថ្មីពាក់ព័ន្ធ និងមានសារៈសំខាន់គ្រប់គ្រាន់ដែលគួរតែទទួលយកសំណើបន្ថែមដែលដាក់មកយឺតយ៉ាវនោះ ដោយរក្សាតុល្យភាពយ៉ាងប្រុងប្រយ័ត្នដោយធៀបទៅនឹងតម្រូវនៃការការពារឱ្យបានពេញលេញដល់សិទ្ធិរបស់ជនជាប់ចោទ (*សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកដទៃទៀត,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដែលទទួលយកសម្ភារៈពាក់ព័ន្ធនឹងការសួរសំណួរដល់ Borovčanin, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-05-88-AR73.1), ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧, កថាខណ្ឌ ៣៧); *សូមមើលផងដែរ* វិធាននីតិវិធី និងភ័ស្តុតាងរបស់តុលាការ ICTY, វិធាន ៦៥*ស្ទួន*; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Sesay និងអ្នកដទៃទៀត,* សេចក្តីសម្រេចលើពាក្យសុំផ្ទាល់មាត់ដែលសុំដកចម្លើយបន្ថែមសម្រាប់សាក្សី TF1-060, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ SCSL (សំណុំរឿងលេខ SCSL-04-15-211), ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៤, កថាខណ្ឌ ១០; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ntawukulilyayo,* សេចក្តីសម្រេចលើ “សំណើបន្ទាន់របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងភាពខ្វះចន្លោះរបស់សហព្រះរាជអាជ្ញាទៅនឹងកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់វត្ថុតាង និងបច្ច័យរបស់វាទៅលើកាលវិភាគសវនាការ” អនុលោមតាមវិធាន ៦៦ និង ៦៨ នៃវិធាននីតិវិធី និងភ័ស្តុតាង, អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-05-82-PT), ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ កថាខណ្ឌ ១៩-២៥។

នោះ[៣១]។ គម្លាតនៃពេលវេលារវាងការចាត់វិធានការយ៉ាងសកម្មក្នុងការតាមរកឯកសារ ឬការពន្យារពេលដោយពុំមានការពន្យល់រវាងការរកឃើញទីកន្លែងនៃឯកសារមួយ និងការដាក់ពាក្យសុំទទួលយកឯកសារនោះជាភស្តុតាង អាចបង្ហាញពីការខកខានមិនបានបំពេញការងារដោយយកចិត្តទុកដាក់ត្រឹមត្រូវ[៣២]។

## ៤.២. <u>ការវិភាគ</u>

២៤. សេចក្តីសម្រេចនាពេលបច្ចុប្បន្នវាយតម្លៃទៅលើប្រភេទឯកសារថ្មីនានាដូចខាងក្រោម៖

ក) *ឯកសារដែលពុំស្ថិតនៅក្នុងសំណុំរឿងនៅពីពេលដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២ ប៉ុន្តែត្រូវបានភាគីស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ មុនពេលចាប់ផ្តើមសវនាការ ដោយអនុលោមតាមវិធាន ៨០(៣)(ឃ) នៃវិធានផ្ទៃក្នុង។*

ឯកសារប្រភេទនេះនៅក្នុងបញ្ជីបឋមរបស់ភាគី ដែលត្រូវបានដាក់មុនពេលចាប់ផ្តើមសវនាការដោយអនុលោមតាមដីកាលើកមុនរបស់អង្គជំនុំជម្រះ (ហើយបន្ទាប់មកត្រូវបានដាក់បញ្ចូលក្នុងបញ្ជីកែសម្រួលរបស់ពួកគេ) រួមមាន៖

i) ឯកសារចំនួន ៤៤៨ ដែលសហព្រះរាជអាជ្ញាបានស្នើ[៣៣]

---

[៣១] *សូមមើលឧទាហរណ៍ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić,* សេចក្តីសម្រេចលើពាក្យសុំរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលស្នើសុំឱ្យពន្លាតរយៈពេលកំណត់ និងការទទួលយកភស្តុតាងបន្ថែម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-94-1-A), ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩៨, កថាខណ្ឌ ៣៥-៤៥; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Krstić,* សេចក្តីសម្រេចលើពាក្យសុំទទួលយកភស្តុតាងបន្ថែមទៀតលើបណ្តឹងឧទ្ធរណ៍, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-98-33-A), ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៣; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Naletilić និង Martinović,* សេចក្តីសម្រេចលើសំណើរួមរបស់ Naletilić សុំដាក់បង្ហាញភស្តុតាងបន្ថែម, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (សំណុំរឿងលេខ IT-98-34-A), ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤, កថាខណ្ឌ ១០; *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង,* សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តីដែលសុំទទួលយកភស្តុតាងបន្ថែម អនុលោមតាមវិធាន ១១៥ នៃវិធាននីតិវិធី និងភស្តុតាង, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTR (សំណុំរឿងលេខ ICRT-98-44A-A), ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៤, កថាខណ្ឌ ៩។

[៣២] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Delalic,* កថាខណ្ឌ ២៨៥-២៨៦។

[៣៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូង នៃការជំនុំជម្រះលើអង្គសេចក្តី, ឯកសារ E109/4, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ក្នុងចំណោមឯកសារចំនួន ៤៥២ ដែលត្រូវ បានដាក់ចំណាត់ថ្នាក់ជាឯកសារថ្មីក្នុងឧបសម្ព័ន្ធនៃ E109/4, ឯកសារចំនួន ៣ (ឯកសារលេខរៀងទី ១៤ នៅក្នុងឯកសារ E109.5; លេខ ៧៨៩ ក្នុងឯកសារ E109/4.12 និងលេខ E181 នៅក្នុង E109.16) ស្ថិតនៅក្នុងសំណុំរឿងរួចហើយក្រោមលេខ D262.2 (ឥឡូវនេះគឺ E/30) និងឯកសារ D2-12 និង D299.1.77 R។ ឯកសារមួយទៀតត្រូវបានដកស្រង់ត្រួតគ្នា (ឯកសារដែលមានលេខរៀង ២១ និង ២២ នៅក្នុងឯកសារលេខ E109/4.19)។

ii) ឯកសារចំនួន ៣៣ ដែលមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានស្នើ[៣៤]

iii) ឯកសារចំនួន ៦ ដែលមេធាវីការពារជនជាប់ចោទ អៀង សារី បានស្នើ[៣៥] និង

iv) ឯកសារចំនួន ១៩ ដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើ[៣៦]

ខ) *ឯកសារដែលត្រូវបានដាក់បន្ទាប់ពីចាប់ផ្តើមសវនាការហើយ ប៉ុន្តែការទទួលយកឯកសារទាំងនោះត្រូវតែបំពេញលក្ខណៈវិនិច្ឆ័យដែលមាននៅក្នុងវិធាន ៨៧(៤)។*

ឯកសារនៅក្នុងប្រភេទនេះរួមមាន៖

i) ឯកសារថ្មីៗដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងសំណើរបស់ខ្លួនចុះថ្ងៃទី ០៥ ខែ កក្កដា និងថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ (*ដែលមានដូចជា* ឈុតវីដេអូរបស់ នួន ជា, កិច្ចសម្ភាសន៍វីដេអូរបស់ ខៀវ សំផន និង សៀវភៅ)

ii) ឯកសារថ្មីចំនួន ៣ ដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់ និងឯកសារចំនួន ១ ដែលមេធាវីការពារជនជាប់ចោទ អៀង សារី ស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះនៅក្នុងបញ្ជីរបស់ពួកគេចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១[៣៧] និង

---

[៣៤] បញ្ជីឯកសារសម្រាប់ដំណាក់កាលដំបូងនៃសវនាការ, ឯកសារ E109/1, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ក្នុងចំណោមឯកសារចំនួន ៣៤ ដែលស្ថិតនៅក្នុងបញ្ជី "ឯកសារថ្មី" ក្នុងឯកសារ E109/1.1, ឯកសារចំនួន ១ (ឯកសារលេខរៀងទី ២ ("កំណត់សម្គាល់ស្តីពីឋានានុក្រមរបស់ អៀង សារី និងខ្មែរក្រហម, Ben Kiernan")) ស្ថិតនៅក្នុងសំណុំរឿងរួចហើយ ក្រោម IS 14.1។

[៣៥] បញ្ជីឯកសារ និងវត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង, ឯកសារ E109/6, ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១។

[៣៦] បញ្ជីឯកសារ និងវត្ថុតាងដែលត្រូវបានកែសម្រួលពាក់ព័ន្ធនឹងចំណុចអង្គហេតុទាំងបួនដែលត្រូវធ្វើសវនាការដំណាក់កាលដំបូងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី, ឯកសារ E109/2, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ក្នុងចំណោមឯកសារចំនួន១៩ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាឯកសារថ្មីក្នុងឯកសារ E109/2.3 ឯកសារចំនួន ១៨ ស្ថិតនៅក្នុងសំណុំរឿងរួចហើយ តាមរយៈការដាក់ភ្ជាប់ទៅនឹងឯកសារមួយទៀត និងពុំមែនដោយសារអានុភាពនៃសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿងឡើយ (*សូមមើល* ការជំទាស់របស់សហព្រះរាជអាជ្ញាទៅនឹងបញ្ជីឯកសារដែលបានស្នើឡើងដោយភាគីសម្រាប់សវនាការរយៈពេល ៣សប្តាហ៍ដំបូង, ឯកសារ E131/1/8, ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ជើងទំព័រ 41) សំណើទី ៣ របស់សហព្រះរាជអាជ្ញា ឧបសម្ព័ន្ធទី១ ។

[៣៧] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអំពីអង្គជំនុំជម្រះដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅក្នុងអំឡុងពេល៣សប្តាហ៍ដំបូងនៃសវនាការជាមួយនឹងឧបសម្ព័ន្ធ ក សម្ងាត់, ឯកសារ E131/1/4, ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ឯកសារលេខរៀងទី 171, លេខរៀងទី 924 ក្នុងឯកសារ

iii) ឯកសារថ្មីចំនួន ១៤ ដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីរបស់ នួន ជា ដែលត្រូវបានដាក់កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២។

២៥. ដើម្បីភាពងាយស្រួល បញ្ជីឯកសារទាំងអស់ដែលអង្គជំនុំជម្រះបានពិនិត្យ សម្រេច ត្រូវបានរៀបចំដាក់បញ្ចូលទៅក្នុងឧបសម្ព័ន្ធមួយនៃសេចក្តីសម្រេចនេះ។

***៤.២.១ ឯកសារដែលពុំស្ថិតនៅក្នុងសំណុំរឿងនៅពេលអង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២ ប៉ុន្តែត្រូវបានភាគីស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះមុនពេលចាប់ផ្តើមសវនាការ***

២៦. បើទោះជាឯកសារប្រភេទនេះអាចត្រូវបានអនុញ្ញាតឲ្យដាក់ អនុលោមតាមវិធាន ៨០ (៣) (ឃ) នៃវិធានផ្ទៃក្នុងក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មកទល់នឹងពេលបច្ចុប្បន្ន ឯកសារខ្លះនៃឯកសារទាំងនេះពុំទាន់ត្រូវបានដាក់ក្នុងសំណុំរឿង ឬដាក់ភ្ជាប់ទៅនឹងសារណារបស់ភាគីនៅឡើយទេ[៣៨]។

២៧. ទោះបីយ៉ាងណា ឯកសារចំនួន ៤៤៤ ក្នុងចំណោមឯកសារថ្មីចំនួន ៤៤៨ ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីកែសម្រួលរបស់សហព្រះរាជអាជ្ញា[៣៩]ឯកសារចំនួន១ក្នុងចំណោម

---

E131/1/4.1)។ បញ្ជីឯកសាររបស់លោក អៀង សារី សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូង, ឯកសារ E131/1/3, ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ (ឯកសារលេខរៀងទី ២០ ក្នុងឯកសារ E131/1/3.2 ដោយយោងទៅលើចម្លើយរបស់សាក្សីដែលមានរហស្សនាម TCW-564 ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១០)។

[៣៨] ឯកសារថ្មីៗគ្រប់ប្រភេទទាំងអស់ អាចត្រូវបានដាក់ទៅក្នុងសំណុំរឿង នៅពេលដែលអង្គជំនុំជម្រះជឿជាក់ថាភស្តុតាងនោះហាក់ដូច ជា*តាមការពិនិត្យជាបឋម* "អាចនាំទៅដល់ការបញ្ជាក់ការពិត" (*សូមមើល* សាលដីកាស្តីពីការពិចារណាឡើងវិញទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ពីការដឹងឮរបស់ជនត្រូវចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង, ឯកសារ D365/2/17, ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០, កថាខណ្ឌ ៤៧)។ *សូមមើលផងដែរ* សេចក្តីសម្រេចអំពីភាពអាចទទួល យកបាននៃភស្តុតាងថ្មី និងសេចក្តីណែនាំដល់ភាគីទាំងអស់, ឯកសារ E5/10/2, ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៩, កថាខណ្ឌ ៦ (ដែលបានសម្រេចថាភស្តុតាងថ្មីត្រូវ "*តាមសេចក្តីបញ្ជាក់ដំបូង* មានភាពពាក់ព័ន្ធទៅនឹងការបញ្ជាក់ការពិត") និងវិធាន ៨៧(៤) (ដែលតម្រូវថាភស្តុតាងក៏ត្រូវ "អាចនាំទៅដល់ការបញ្ជាក់ការពិត" ទាក់ទិននឹងការទទួលយកភស្តុតាងថ្មីក្នុងអំឡុងពេលសវនាការ)។

[៣៩] ដែលរួមមានឯកសារទាំងអស់ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជាឯកសារថ្មី និងត្រូវបានសម្គាល់ដោយពណ៌បៃតងក្នុងឧបសម្ព័ន្ធនៃ ឯកសារ E109/4 ដោយពុំរួមបញ្ចូលឯកសារចំនួន ៤ ដែលត្រូវបានរាយនាមនៅក្នុងជើងទំព័រ ៤៥ ខាងក្រោម និងឯកសារចំនួន៤ ត្រូវបានកំណត់ក្នុងជើងទំព័រ ៣៣ ខាងលើ។

00804399



ឯកសារថ្មីចំនួន ៦ នៅក្នុងបញ្ជីកែសម្រួលរបស់ អៀង សារី[៤០] ឯកសារចំនួន ៥ ក្នុងចំណោមឯកសារថ្មីចំនួន ៣៣ នៅក្នុងបញ្ជីកែសម្រួលរបស់ ខៀវ សំផន[៤១] និងឯកសារចំនួន ១៩ នៅក្នុងបញ្ជីកែសម្រួលរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី[៤២] ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ឬត្រូវបានភ្ជាប់ជាមួយឯកសារផ្សេងៗទៀត ដូច្នេះភាគី និងអង្គជំនុំជម្រះអាចពិនិត្យមើលឯកសារទាំងនេះបាន។ បន្ទាប់ពីបានពិនិត្យឯកសារចំនួន ៤៦៩ នេះមក និងដោយបានយល់ឃើញថា ឯកសារចំនួន ៤៦៥ នៃឯកសារទាំងនេះ *តាមការពិនិត្យមើលជាបឋម (prima facie) នាំទៅដល់ការបញ្ជាក់ការពិត* ទើបអង្គជំនុំជម្រះបានដាក់ឯកសារចំនួន ៣៥ ក្នុងចំណោមឯកសារទាំងនេះ ទៅក្នុងសំណុំរឿង ហើយនឹងដាក់ឯកសារចំនួន ៤៣០ ផ្សេងទៀតទៅក្នុងសំណុំរឿងនាពេលឆាប់ៗខាងមុខ[៤៣]។ ឯកសារនៅសល់ចំនួន ៤ ជាឯកសារពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ ហើយនៅពេលបច្ចុប្បន្ន ឯកសារទាំងនេះពុំពាក់ព័ន្ធទៅនឹងវិសាលភាពនៃ

---

[៤០] ឯកសារលេខរៀងទី ៥ ក្នុងឯកសារ E109/6.2 មាននៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមចំនួន ២ ដង ក្រោមលេខ ERN S 00047300-00047329 និង S 00047272-00047299។ ឯកសារទាំងនេះស្រដៀងគ្នាច្រើនប៉ុន្តែពុំដូចគ្នាឡើយ។

[៤១] ឯកសារលេខរៀងទី៣ ("កិច្ចសន្ទនាជាមួយលោក PECH Lim Kuon"), លេខរៀងទី៤ ("បានភៀសខ្លួនដោយសារភាពសាហាវឃោរឃៅរបស់ខ្មែរក្រហម), លេខរៀងទី៥ (កម្ពុជា៖ Two views from inside"), លេខរៀងទី6 ("Defecting Khmer Rouge helicopter pilot tells of life in Phnom Penh") និងលេខរៀងទី24 ("AFP-164, Arrivee d"une delegation laotienne en visite officielle au Cambodge") ក្នុងឯកសារ E109/1.1 ស្ថិតនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមក្រោមលេខ ERNs 00389075-00389077, 00005745, 00005751-00005752, 00005730 និង 00391115 ដាច់ដោយឡែកពីគ្នា។ ឯកសារផ្សេងខ្លះទៀតដែលស្ថិតនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម ហាក់ដូចជាឆ្លើយតបទៅនឹងឯកសារដែលត្រូវបានកំណត់ក្នុងឯកសារ E109/1.1 (*ឧទាហរណ៍* ឯកសារលេខរៀងទី 15, "កម្ពុជា៖ The verdict is guilty on Nixon and Kissinger" ហាក់ដូចជាឆ្លើយតបទៅនឹងលេខ ERN 00006030-00006033), ប៉ុន្តែដោយហេតុថាមេធាវីការពារជនជាប់ចោទ ខៀវ សំផន ពុំទាន់បានផ្តល់លេខ ERN សម្រាប់ឯកសារទាំងនេះ អង្គជំនុំជម្រះពុំអាចមានភាពច្បាស់លាស់ឡើយ។

[៤២] ឯកសារលេខរៀងទី ១ ដល់លេខរៀងទី ១៨ ក្នុងឯកសារ E109/2.3។

[៤៣] *សូមមើល*កថាខណ្ឌ ៨, ខាងលើ។ ទោះបីឯកសារចំនួន ១៨ ក្នុងចំណោមឯកសារថ្មីៗដែលសហមេធាវីនាំមុខតំណាងដើមបណ្តឹង រដ្ឋប្បវេណីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ មានលេខយោងសំណុំរឿងតែតាមរយៈការដាក់ក្នុងឯកសារមួយដាច់ដោយឡែកក៏ដោយ (*សូមមើល* ជើងទំព័រ ៣៣ ខាងលើ) អង្គជំនុំជម្រះយល់ថាជាការពុំចាំបាច់ដែលត្រូវដាក់ឯកសារទាំងនេះឡើងវិញក្រោមលេខយោងសំណុំរឿងផ្សេង។

សវនាការលើសំណុំរឿង ០០២/០១ ដោយសារតែការផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះ[៦៤]។

២៨. ឯកសារប្រភេទនេះដែលនៅសល់ចំនួន ៣៧ ពោលគឺ ឯកសារថ្មីចំនួន ៤ ក្នុងបញ្ជីកែសម្រួលរបស់សហព្រះរាជអាជ្ញា[៦៥] ឯកសារចំនួន ២៨ ក្នុងចំណោមឯកសារថ្មីៗក្នុងបញ្ជីកែសម្រួលរបស់ ខៀវ សំផន[៦៦] និងឯកសារចំនួន ៥ នៃឯកសារនៅក្នុងបញ្ជីកែសម្រួលរបស់ អៀង សារី[៦៧] ពុំទាន់ត្រូវបានដាក់ទៅក្នុងឃ្លាំងផ្ទុកឯកសាររួម ឬអង្គជំនុំជម្រះពុំទាន់អាចឃើញនៅឡើយទេ។ បើទោះជាភាគីមានបន្ទុកក្នុងការដាក់ឯកសារឱ្យបានទាន់ពេលវេលាក៏ដោយ ក៏ក្នុងករណីពិសេស អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគីដាក់ឯកសារដែលនៅសេសសល់ទាំងនេះទៅក្នុងឃ្លាំងផ្ទុកឯកសាររួម មិនឱ្យលើសពីថ្ងៃ សុក្រ ទី ១១ ខែ ឧសភា ឆ្នាំ ២០១២។ ប្រសិនបើផុតកាលបរិច្ឆេទខាងលើ ភាគីមិនទាន់ដាក់ឯកសារទាំងនេះទៀត អង្គជំនុំជម្រះអាចចាត់ទុកការប៉ុនប៉ងណាមួយនៅពេលក្រោយក្នុងការសំអាងលើឯកសារទាំងនេះ ថាជាសំណើសុំដាក់ភស្តុតាងថ្មី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

២៩. នៅពេលដែលឯកសារខាងលើត្រូវបានដាក់ឱ្យអង្គជំនុំជម្រះអាចពិនិត្យមើលបាន ឯកសារទាំងនោះនឹងត្រូវវាយតម្លៃ និងដាក់ទៅក្នុងសំណុំរឿង នៅពេលដែល *ការពិនិត្យជាបឋម (prima facie)* អាចនាំទៅដល់ការបញ្ជាក់ការពិត។ ទោះបីជាយ៉ាងណា ឯកសារទាំងអស់ក្នុងប្រភេទនេះ

---

[៦៤] ឯកសារលេខរៀងទី 356 ក្នុងឯកសារ E109/4.5 (ERN 00420026-00420042) និងលេខរៀងទី 56 (ERN P00513616), លេខរៀងទី 63 (ERN P00513407) និងលេខរៀងទី 90 (ERN P00513619) ក្នុងឯកសារ E109/4.15, *សូមមើលបន្ថែម* សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ, ឯកសារ E138, ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៦៥] ឯកសារលេខរៀងទី 115 (ដែលអាចស្ថិតនៅក្នុងសំណុំរឿងរួចហើយក្រោមលេខ D56-Doc. 437) និងលេខរៀង 233 ក្នុងឯកសារ E109/4.1, លេខរៀងទី 17 ក្នុងឯកសារ E109/4.5 (ឯកសារដែលមានលេខ ERN 00002196-00002203 ពុំត្រូវទៅនឹងការរៀបរាប់របស់សហព្រះរាជអាជ្ញាអំពីឯកសារដែលមានលេខរៀងទី 17 ឡើយ), និងឯកសារលេខរៀងទី 230 ក្នុងឯកសារ E109/4.15។

[៦៦] ឯកសារលេខរៀងទី 1 ("Entretien avec Laurence PICQ par Jean-Paul Desgoutte"), លេខរៀងទី 7 ("Temoignage de Philippe JULIAN") ដល់លេខរៀងទី 23 ("Memorandum de conversation entre le President de l"Indonesie et Ford et Kissinger") និងលេខរៀងទី 25 ("A Special Supplement: Cambodia, The New York Review of Books, Noam Chomsky") ដល់លេខរៀងទី 34 ("ឯកសារ ina.fr, Intervention de feu M. le President Pompidou sur la grace a Touvier") ក្នុងឯកសារ E109/1.1។

[៦៧] ឯកសារលេខរៀងទី 1, ទី 3, ទី 4, ទី 6 និងទី 8 ក្នុងឯកសារ E109/6.2។

ដែលត្រូវបានដាក់ក្នុងសំណុំរឿងនឹងទទួលចំណាត់ថ្នាក់ E3 តែនៅក្រោយពេលអង្គជំនុំជម្រះសាលាដំបូងបានស្តាប់ និងបានសម្រេចលើការជំទាស់ជាក់លាក់ទៅនឹងឯកសារទាំងនេះប៉ុណ្ណោះ ប្រសិនបើមាន ដោយអនុលោមតាមវិធាន ៨៧(៣)(ក)-(ង) នៃវិធានផ្ទៃក្នុង និងទម្រង់បែបបទដែលមានរៀបរាប់ខាងលើ (ផ្នែក ៤.១.១)[៤៨]។ សវនាការនៅពេលបន្ទាប់មកទៀតសម្រាប់គោលបំណងនេះនឹងត្រូវកំណត់កាលបរិច្ឆេទនាពេលសមស្របខាងមុខ។

### *៤.២.២ ឯកសារដែលត្រូវដាក់បន្ទាប់ពីចាប់ផ្តើមសវនាការ ហើយត្រូវបំពេញលក្ខណៈវិនិច្ឆ័យនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង*

#### *៤.២.២.១ ឯកសារដែលសហព្រះរាជអាជ្ញាបានស្នើសុំដាក់*

៣០. សហព្រះរាជអាជ្ញាអះអាងថា កិច្ចសម្ភាសន៍វីដេអូរបស់ ខៀវ សំផន "ត្រូវបានបង្ហោះតាមប្រព័ន្ធអ៊ិនធឺណែតដោយតតិយភាគី ដែលអះអាងថា ជា ខៀវ សំផន និងត្រូវបានការិយាល័យសហព្រះរាជអាជ្ញារកឃើញកាលពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១១"[៤៩]។ បើទោះជាពុំមានការបញ្ជាក់ថាតើកិច្ចសម្ភាសន៍វីដេអូ ខៀវ សំផន ត្រូវបានបង្ហោះតាមប្រព័ន្ធអ៊ិនធឺណែតនៅពេលណា អង្គជំនុំជម្រះចាត់ទុកថាសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបន្ថែមកិច្ចសម្ភាសន៍នេះទៅក្នុងសំណុំរឿងត្រឹមថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ ក្នុងកាលៈទេសៈទាំងនេះ បញ្ជាក់ឱ្យឃើញអំពីការយកចិត្តទុកដាក់សមស្រប ហេតុដូច្នេះអង្គជំនុំជម្រះឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់វីដេអូនេះចូលក្នុងសំណុំរឿង។

៣១. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ខ្សែភាពយន្តឯកសារ ដែលឈុតវីដេអូ នួន ជា ជាផ្នែកមួយនៅក្នុងភាពយន្តនេះ មាននៅក្នុងបញ្ជីឯកសាររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់នៅខែ មេសា និងខែ កក្កដា ឆ្នាំ ២០១១[៥០]។ ដូច្នេះ អង្គជំនុំជម្រះបានពិនិត្យភាពយន្ត ឯកសារនេះរួចហើយនៅពេលអង្គជំនុំជម្រះពិនិត្យទៅលើឯកសារថ្មីៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងបានដាក់ឯកសារនេះទៅក្នុងសំណុំរឿងដោយ

---

[៤៨] *សូមមើលបន្ថែមទៀត* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5", ឯកសារ E131/1, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ (ដោយកត់សម្គាល់នូវកាតព្វកិច្ចរបស់ភាគីដែលស្នើសុំដាក់ឯកសារមួយនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងការធានាឱ្យឯកសាររបស់ខ្លួនមានគ្រប់ភាសាផ្លូវការទាំងអស់)។

[៤៩] សំណើទីពីររបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៣។

[៥០] វត្ថុតាងលេខ ១ នៅក្នុងឯកសារ E109/2.3 ជាវត្ថុតាងលេខ ១ នៅក្នុងឯកសារ E9/32.3។

យល់ឃើញថាឯកសារនេះ *បើតាមការពិនិត្យជាបឋម (prima facie)* នាំទៅរកការបញ្ជាក់ការពិត។ ដូច្នេះ សំណើទីបីរបស់សហព្រះរាជអាជ្ញាមិនចាំបាច់ធ្វើការដោះស្រាយនៅពេលនេះទេ។ ដោយសារតែឈុតវីដេអូ នួន ជា គឺជាការដកស្រង់ពីខ្សែភាពយន្តឯកសារនេះ អង្គជំនុំជម្រះយល់ឃើញថាវាមិនមែនជាឯកសារដាច់ដោយឡែកឡើយ ហើយឯកសារនេះនឹងត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងជាមួយនឹងភាពយន្តឯកសារនោះ។

៣២. ពាក់ព័ន្ធនឹងសៀវភៅ ដែលត្រូវបានបោះពុម្ពនៅឆ្នាំ ២០១០ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាខកខានពុំបានពន្យល់អំពីមូលហេតុដែលពួកគេពុំអាចទទួលបានសៀវភៅនេះតាមរយៈការអនុវត្តដោយយកចិត្តទុកដាក់សមស្របមុនពេលបណ្ណាល័យ អ.វ.ត.ក ទទួលបានសៀវភៅនេះ និងមុនពេលបើកសវនាការ។ ទោះបីជាយ៉ាងណា ដោយហេតុថា ខ្សែភាពយន្តឯកសារគឺជាឯកសារមូលដ្ឋាន ដែលពាក់ព័ន្ធជិតស្និទ្ធនឹងសៀវភៅនេះ អង្គជំនុំជម្រះយល់ថាជាផលប្រយោជន៍នៃយុត្តិធម៌ដែលត្រូវវាយតម្លៃទៅលើប្រភពទាំងនេះរួមគ្នា ដូច្នេះហើយអង្គជំនុំជម្រះនឹងវាយតម្លៃប្រភពទាំងពីរនេះដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដូចគ្នា។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់សៀវភៅទៅក្នុងសំណុំរឿង[៥១]។

៣៣. សវនាការមួយនឹងត្រូវគ្រោងរៀបចំឡើងនៅពេលខាងមុខសមស្រប ដើម្បីអនុញ្ញាតឱ្យភាគីលើកការជំទាស់ពាក់ព័ន្ធទៅនឹងឯកសារប្រភេទនេះទាំងអស់ (ពោលគឺ កិច្ចសម្ភាសន៍វីដេអូ ខៀវ សំផន , សៀវភៅ និងភាពយន្តឯកសារ) អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

### ៤.២.២.២ ឯកសារដែលមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានកំណត់អត្តសញ្ញាណយឺតពេល

៣៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារចំនួន ២ នៃឯកសារថ្មីចំនួន ១៤ ដែលត្រូវបានកំណត់ក្នុងបញ្ជី នួន ជា ក៏ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីបឋមរបស់សហព្រះរាជអាជ្ញា និងបញ្ជីកែសម្រួលដែលត្រូវបានដាក់កាលពីថ្ងៃទី ១៩ ខែ មេសា និងថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ដាច់ដោយឡែកពីគ្នា[៥២]។ ហេតុដូច្នេះ ឯកសារទាំងនេះត្រូវបានអង្គជំនុំជម្រះពិនិត្យរួចរាល់ នៅក្នុងអំឡុង

---

[៥១] សៀវភៅ កិច្ចសម្ភាសន៍ជាខ្សែវីដេអូរបស់ ខៀវ សំផន ព្រមទាំងឈុតវីដេអូ នួន ជា នៅពេលបច្ចុប្បន្នក៏ស្ថិតនៅក្នុងសំណុំរឿងដែរដោយសារតែ ត្រូវបានភ្ជាប់ទៅជាមួយឯកសារមួយទៀត (ឯកសារ E152.2 និង E152.1.1R-E152.1.54R និង E93/7.3R)។ ទោះយ៉ាងណា អង្គជំនុំជម្រះយល់ថាជាការពុំចាំបាច់ដែលត្រូវដាក់ឯកសារទាំងនេះម្តងទៀត ក្រោមលេខយោងសំណុំរឿងផ្សេង។

[៥២] ឯកសារលេខ 22 និងលេខ 23 ក្នុងឯកសារ E131/1/13.1, ដែលលេចចេញជាឯកសារលេខ 89 និងលេខ 90 ក្នុងឯកសារ E109/4.19 (*សូមមើល* ឯកសារ E131/1/14, ជើងទំព័រ ២)។

ពេលនៃការពិនិត្យមើលរបស់ខ្លួនទៅលើឯកសារថ្មីៗរបស់សហព្រះរាជអាជ្ញា និងត្រូវបានដាក់ក្នុងសំណុំរឿងរួចហើយ បន្ទាប់ពី *ការពិនិត្យជាបឋម* ឃើញថា អាចនាំទៅដល់ការបញ្ជាក់ការពិត។

៣៥. ពាក់ព័ន្ធនឹងឯកសារចំនួន ១២ ដែលនៅសេសសល់ អង្គជំនុំជម្រះធ្លាប់បានកត់សំគាល់ឃើញថាមេធាវីការពារជនជាប់ចោទ នួន ជា បានខកខានពុំបានគោរពតាមពេលវេលាកំណត់របស់អង្គជំនុំជម្រះក្នុងការដាក់បញ្ជីឯកសារទេ ទោះបីមេធាវីការពារក្តីធ្លាប់ត្រូវបានព្រមានថា ការខកខាននេះនឹងប៉ះពាល់ទៅដល់លទ្ធភាពរបស់ខ្លួនក្នុងការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការក៏ដោយ[៥៣]។ ហេតុដូច្នេះ អង្គជំនុំជម្រះចាត់ទុកការលើកឡើងអំពីឯកសារចំនួនទាំង ១២ នេះ ជាសំណើសុំដាក់ឯកសារភស្តុតាងថ្មី ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ បើទោះបីជាមេធាវីការពារជនជាប់ចោទ នួន ជា ចាត់ទុកសារណាដែលមានភ្ជាប់បញ្ជីរបស់ខ្លួន ថាជាសារណាមួយដែលមានសំអាងហេតុសម្រាប់គោលបំណងនៃវិធាន ៨៧(៤) នៃ វិធានផ្ទៃក្នុងក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សារណានេះពុំពន្យល់មូលហេតុនៃការពុំមានឯកសារនោះ នៅមុនពេលបើកសវនាការ និងមូលហេតុដែលឯកសារទាំងនោះពុំអាចត្រូវបានរកឃើញពីពេលមុន បើទោះជាមេធាវីការពារជនជាប់ចោទ នួន ជា បានស្វែងរកដោយយកចិត្តទុកដាក់ក៏ដោយនោះ[៥៤]។

៣៦. បើទោះជាមេធាវីការពារជនជាប់ចោទ នួន ជា ខ្វះការយកចិត្តទុកដាក់សមស្របក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់យុត្តិសាស្ត្រអន្តរជាតិ ដែលអនុញ្ញាតជាករណីលើកលែងឱ្យអង្គជំនុំជម្រះទទួលយកសម្ភារៈ ដែលត្រូវបានដាក់ដោយពុំទាន់ពេលវេលា ដោយឯកសារនោះពាក់ព័ន្ធ និងមានសារៈសំខាន់គ្រប់គ្រាន់ក្នុងការផ្តល់យុត្តិកម្មចំពោះការបន្ថែមដោយយឺតពេលរបស់ខ្លួននេះ នៅពេលថ្លឹងថ្លែងអំពីតម្រូវការក្នុងការការពារសិទ្ធិរបស់ជនជាប់ចោទឱ្យបានគ្រប់គ្រាន់[៥៥]។ ជាទូទៅ អង្គជំនុំជម្រះនឹងពិចារណាទៅលើឯកសារទាំងនេះ តែនៅពេលណាដែលអង្គជំនុំជម្រះចាត់ទុក

[៥៣] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5", ឯកសារ E131/1, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១, ទំព័រ ៤។

[៥៤] សំណើរបស់ នួន ជា កថាខណ្ឌ ៧។

[៥៥] *សូមមើល ឧទាហរណ៍ រដ្ឋអាជ្ញា ទល់នឹង Popovic et al.,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចទទួលយកសម្ភារៈទាក់ទិននឹងការសួរសំណួរ Borovcanin, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (លេខសំណុំរឿង IT-05-88-AR73.1), ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧, កថាខណ្ឌ ៣៧។ *សូមមើលផងដែរ* ជើងទំព័រ ៣០ (ខាងលើ) និងអត្ថបទអម។

ឯកសារទាំងនេះថាជាឯកសារដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីបញ្ចៀសការសម្រេចដោយមិនមានភាពយុត្តិធម៌។

៣៧. អង្គជំនុំជម្រះបានពិនិត្យមើលឯកសារនានាក្នុងចំណោមឯកសារចំនួន ១២ ដែលនៅសេសសល់ ដែលខ្លួនអាចពិនិត្យមើលបាននៅពេលបច្ចុប្បន្ន ហើយបានពិចារណាឃើញថា ឯកសារភាគច្រើនជាឯកសារពុំពាក់ព័ន្ធ និងពុំមែនជាឯកសារដោះបន្ទុក[៥៦]។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានដាក់ឯកសារទាំងនោះទៅក្នុងសំណុំរឿង។ ប៉ុន្តែ អង្គជំនុំជម្រះសូមបញ្ជាក់ថា ឯកសារទាំងនេះអាចត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ប្រសិនបើឯកសារទាំងនេះត្រូវបានរកឃើញថាបានបំពេញលក្ខណៈវិនិច្ឆ័យនៅក្នុងវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះនឹងផ្តល់ឱកាសសម្រាប់ភាគីនៅពេលក្រោយ ដើម្បីលើកការជំទាស់ប្រសិនបើមាន ចំពោះឯកសារទាំងនេះ ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យទាំងឡាយ ស្របតាមក្របខណ្ឌនីតិវិធីខាងលើ (ផ្នែក ៤.១.១)។

### *៤.២.២.៣ ឯកសារដែលមាននៅក្នុងបញ្ជីកែសម្រួលរបស់ភាគីដែលពុំត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីដើម*

៣៨. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ផ្ទុយទៅនឹងលក្ខខណ្ឌដែលមានចែងក្នុងដីការបស់ខ្លួនចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ភាគីខ្លះបានដាក់បញ្ចូលទៅក្នុងបញ្ជីកែសម្រួលរបស់ពួកគេនូវឯកសារដែលមិនត្រូវបានកំណត់ក្នុងបញ្ជីដើម ដែលត្រូវបានដាក់កាលពីខែ មេសា ឆ្នាំ ២០១១[៥៧]។ ករណីនេះកើតមានចំពោះឯកសារចំនួន ៣ នៃឯកសារថ្មីៗដែលស្ថិតក្នុងបញ្ជីរបស់សហព្រះរាជ

---

[៥៦] ឯកសារចំនួនត្រឹមតែ ១១ ក្នុងចំណោមឯកសារថ្មីចំនួន ១២ ដូចដែលបានបញ្ជាក់ខាងលើ ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងបញ្ជីរបស់ នួន ជា ត្រូវបានដាក់ភ្ជាប់ទៅជាមួយនឹងបញ្ជីរបស់ នួន ជា ផ្ទាល់ នោះគឺឯកសារលេខ 24 (ឯកសារ E131/1/13.2), ឯកសារលេខ 25 (ឯកសារ E131/1/13.12), ឯកសារលេខ 26 (ឯកសារ E131/1/13.3), ឯកសារលេខ 27 (ឯកសារ 131/1/13.4), ឯកសារលេខ 28 (ឯកសារ E131/1/13.5), ឯកសារលេខ 29 (ឯកសារ E131/1/13.6), ឯកសារលេខ 31 (E131/1/13.7), ឯកសារលេខ 32 (ឯកសារ E131/1/13.8), ឯកសារលេខ ៣៣ (ឯកសារ E131/1/13.9), ឯកសារលេខ 34 (ឯកសារ E131/1/13.10) និងឯកសារ E 35 (ឯកសារ E131/1/13.11) ក្នុងឯកសារ E131/1/13.1។ អង្គជំនុំជម្រះបានរក្សា ឯកសារទាំងនេះទុកក្នុងសំណុំរឿងក្រោមលេខយោងខាងលើ។

[៥៧] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5", ឯកសារ E131/1, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១, ទំព័រ ១។

អាជ្ញា ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១ និងឯកសារមួយក្នុងចំណោមឯកសារថ្មីៗនៅក្នុងបញ្ជីរបស់ អៀង សារី ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១[៥៨]។ ដោយហេតុថាអង្គជំនុំជម្រះពុំបានទទួលការជូនដំណឹងអំពីចេតនារបស់ភាគីក្នុងការសំអាងលើឯកសារទាំងនេះ រហូតដល់ពេលដែលភាគីដាក់បញ្ជីកែសម្រួលរបស់ខ្លួនកាលពីខែ វិច្ឆិកា ឆ្នាំ ២០១១ បន្ទាប់ពីការបើកសវនាការនោះ ការដាក់បន្ថែមឯកសារទាំងនេះនឹងត្រូវចាត់ទុកជាសំណើសុំដាក់ភស្តុតាងថ្មី ដោយអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង។ មកទល់ពេលបច្ចុប្បន្ន ភាគីពុំទាន់បានខិតខំបំពេញលក្ខណៈវិនិច្ឆ័យ ដែលមានចែងនៅក្នុងអនុវិធាននេះនៅឡើយទេ ពាក់ព័ន្ធនឹងឯកសារទាំងនេះ។

៣៩. យ៉ាងណាក៏ដោយ ឯកសារមួយក្នុងចំណោមឯកសារដែលបានលើកឡើងខាងលើ ដែលស្ថិតនៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញា គឺជាប្រវត្តិរូបរបស់សាក្សីម្នាក់ដែលបានផ្តល់សក្ខីកម្មរួចហើយក្នុងសំណុំរឿង ០០២/០១។ ឯកសារមួយនេះត្រូវបានផ្តល់ចំណាត់ថ្នាក់ E3 រួចរាល់ហើយ បន្ទាប់ពីវាត្រូវបានលើកយកមកសំអាងក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សីរូបនោះ និងនៅពេលពុំមានការជំទាស់ណាមួយទៅនឹងឯកសារនេះ[៥៩]។ ក្នុងកាលៈទេសៈបែបនេះ និងដោយយោងទៅដល់ទំនាក់ទំនងជិតស្និទ្ធរវាងឯកសារនេះ និងសក្ខីកម្មរបស់ម្ចាស់ឯកសារនោះ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន អង្គជំនុំជម្រះបានឯកភាពទៅនឹងការដាក់ចំណាត់ថ្នាក់ E3 ដល់ឯកសារនេះ។ ឯកសារចំនួន ២ ផ្សេងទៀត គឺទំនងជាចម្លើយរបស់បុគ្គលដែលគ្រោងនឹងផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនៅពេលក្រោយ[៦០]។ ទោះជាមានការកំណត់ឯកសារទាំងនេះថាពុំបានដាក់ទាន់ពេលវេលាក៏ដោយ ក៏អង្គជំនុំជម្រះនឹងអនុញ្ញាតជាករណីលើកលែងឲ្យដាក់សម្ភារៈ/ឯកសារនេះ ចូលទៅក្នុងសំណុំរឿង និងដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ ហើយ

---

[៥៨] ឯកសារលេខ 171, 924 និង 928 ក្នុងឯកសារ E131/1/4.1 (សហព្រះរាជអាជ្ញា) និងឯកសារលេខ20 ក្នុងឯកសារ E131/1/3.2 (អៀង សារី)។ ឯកសារលេខ 928 ក្នុងឯកសារ E131/1/4.1 និងឯកសារលេខ 20 ក្នុងឯកសារ E131/1/3.2 សំដៅទៅឯកសារដូចគ្នានោះគឺ កំណត់ហេតុនៃកិច្ចសម្ភាសន៍ជាមួយសាក្សីដែលមានរហស្សនាម TCW-564។

[៥៩] ប្រវត្តិរូបរបស់ឈ្មោះ ឡុង នរិន្ទ *ហៅ* រិទ្ធ, ឯកសារ E3/128 (ឯកសារលេខ 171 ក្នុងឯកសារ E131/1/4.1)។ *សូមមើលផងដែរ* ប្រតិចារឹក, ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០១១, ទំព័រ ២-៥៨។

[៦០] កិច្ចសម្ភាសន៍ជាមួយសាក្សីដែលមានរហស្សនាម TCW-564 (ឯកសារលេខ 928 ក្នុងឯកសារ E131/1/4.1, ក៏ត្រូវបានដាក់លេខរៀងជាឯកសារលេខ ២០ ក្នុងឯកសារ E131/1/3.2)។ កិច្ចសម្ភាសន៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-142 (ឯកសារលេខ 924 ក្នុងឯកសារ E131/1/4.1)។ *សូមមើលបន្ថែមទៀត* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារ E172។

ភាគីមាននានាសិទ្ធិលើកការជំទាស់ទៅលើឯកសារទាំងនេះបាន ប្រសិនបើមាន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង នាពេលសមស្របខាងមុខ។

**តាមសំអាងហេតុដូចដែលបានរៀបរាប់ខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**បដិសេធ** អំណះអំណាងរបស់មេធាវីការពារជនជាប់ចោទ នួន ជា (ឯកសារ E131/1/13) ដែលថាខ្លួនអាចដាក់ឯកសារនានា ដែលខ្លួនចាត់ទុកថាជាឯកសារពាក់ព័ន្ធនឹងសវនាការ នៅគ្រប់ដំណាក់កាលទាំងអស់ក្នុងអំឡុងពេលសវនាការ ដោយហេតុថាអំណះអំណាងនេះផ្ទុយទៅនឹងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក។

**បដិសេធ** សំណើរបស់មេធាវីការពារជនជាប់ចោទ អៀង សារី ដែលស្នើសុំដាក់បញ្ចូលមាតិកានៃឯកសារនានាដែលមាននៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម (ឯកសារ E9/24) ទៅក្នុងវិសាលភាពនៃឯកសារទាំងឡាយដែលមេធាវីអាចយកមកធ្វើជាសំអាងនៅក្នុងសវនាការ ដោយហេតុថាសំណើនេះផ្ទុយទៅនឹងក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក និងលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។

**សម្រេច** ថាឯកសារថ្មីចំនួន ៤៦៥ ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងកថាខណ្ឌ ២៧ នៃសេចក្តីសម្រេចនេះ និង ដែលអង្គជំនុំជម្រះ និងភាគី អាចពិនិត្យមើលបាន *តាមការពិនិត្យជាបឋម* នោះ អាចនាំទៅដល់ការបញ្ជាក់ការពិត។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារចំនួន ៣៥ ក្នុងចំណោមឯកសារទាំងនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ដោយសារអានុភាពនៃសេចក្តីសម្រេច E185 (កថាខណ្ឌ ៨) ហើយដាក់ឯកសារចំនួន ៤៣០ ដែលនៅសេសសល់ក្នុងចំណោមឯកសារថ្មីចំនួន ៤៦៥ ទៅក្នុងសំណុំរឿង។

**បដិសេធ** មិនដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវឯកសារថ្មីដែលលេខរៀងទី ៣៥៦ នៅក្នុងឯកសារ E109/4.5 (ERN 00420026-00420042), លេខរៀងទី ៥៦ ដែលមាននៅក្នុងឯកសារ E109/4.15 (ERN P00513616), លេខរៀងទី ៦៣ ក្នុងឯកសារ E109/4.15 (ERN P00513407) និងលេខរៀងទី ៩០ នៅក្នុងឯកសារ E109/4.15 (ERN P00513619) ដោយអានុភាពនៃសេចក្តីសម្រេចនេះ ត្រង់កថាខណ្ឌ ២៧។

**បង្គាប់** ឱ្យដាក់ទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមនូវឯកសារថ្មីចំនួន ៣៧ ដែលត្រូវបានកំណត់ក្នុងកថាខណ្ឌ ២៨ នៃសេចក្តីសម្រេចនេះ មិនឱ្យហួសពីថ្ងៃ សុក្រ ទី ១១ ខែ ឧសភា ឆ្នាំ ២០១២ ដើម្បីអនុញ្ញាតឱ្យ

00804407



អង្គជំនុំជម្រះធ្វើការវាយតម្លៃថាតើ ឯកសារទាំងនេះ *តាមការពិនិត្យជាបឋម* អាចនាំទៅដល់ការបញ្ជាក់ការពិត ហើយត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿងដែរ ឬយ៉ាងណា។

**ដាក់** កិច្ចសម្ភាសន៍ ខៀវ សំផន ជាខ្សែវីដេអូ ឈុតវីដេអូ នួន ជា និងសៀវភៅ ទៅក្នុងសំណុំរឿង។

**ដាក់** ក្នុងសំណុំរឿងនូវឯកសារថ្មីចំនួន ៣ ដូចមានរៀបរាប់ក្នុងកថាខណ្ឌ ៣៩ ព្រមទាំងឯកសារថ្មីចំនួន ១១ ដូចមានរៀបរាប់ក្នុងកថាខណ្ឌ ៣៧ នៃសេចក្ដីសម្រេចនេះ ទោះបីជាភាគីបានកំណត់ឯកសារទាំងនោះដោយយឺតយ៉ាវក៏ដោយ។

**ជូនដំណឹង** ថា អង្គជំនុំជម្រះនឹងផ្ដល់ឱកាសទៅភាគីនៅពេលក្រោយ ដើម្បីស្ដាប់ការជំទាស់ ប្រសិនបើមាន ចំពោះសម្ភារៈ/ឯកសារទាំងអស់ ដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ឬស្នើសុំដាក់នៅចំពោះអង្គជំនុំជម្រះ ដោយអានុភាពនៃសេចក្ដីសម្រេចនេះ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

ភ្នំពេញ ថ្ងៃទី៣០ ខែ មេសា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**